-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥

-បានឃើញព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១** .- ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៣.០៤៥ លានរៀល (បីពាន់សែសិបប្រាំលានរៀលគត់) ពីជំពូក១០ (សម្ភារៈ និងប្រាក់បំណាច់) ទៅកាន់ជំពូក១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈនិងការផ្គត់ផ្គង់ទូទៅ) របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសណ្តាប់ធ្នាប់ សំរាប់ការគ្រប់គ្រង ឆ្នាំ២០០០ ។

**មាត្រា ២** .- ឥណទានថវិកា ក្នុងមាត្រា១ខាងលើ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់ទូទាត់ថ្លៃផ្គត់ផ្គង់ ឯកសណ្ឋានសត្តិ និងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ ឆ្នាំ២០០០ ។

**មាត្រា ៣** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យ លេខ ៥៣ អនក្រ.បក

## ស្តីពី

## ការលុបឈ្មោះមន្ត្រី-បុគ្គលិក រាជការស៊ីវិល ចេញពីក្របខ័ណ្ឌ និង ពីតារាងបៀវត្ស នៅដំណាក់កាលទី ១ នៃការធ្វើជំរឿនមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/០៣៩៩/៧២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-បានឃើញអនុក្រឹត្យលេខ ៥១អនក្រ.បក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-បានឃើញសេចក្តីសំរេចលេខ ៦០សសរ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការធ្វើជំរឿនមន្ត្រីរាជការ និងវិភាគមុខងារ

-យោងស្មារតីអង្គប្រជុំគណៈរដ្ឋមន្ត្រី ស្តីពីការងារកំណែទំរង់រដ្ឋបាល ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០០

## សំរេច

**មាត្រា ១ .-**

ត្រូវបានលុបឈ្មោះចេញពីក្របខ័ណ្ឌ នូវមន្ត្រី បុគ្គលិក រាជការស៊ីវិល ដែលបានអវត្តមានគ្មានមូលហេតុ នៅតាមក្រសួង ស្ថាប័ន និងខេត្ត-ក្រុងនានា ចំនួន ៣.០៦៣ នាក់ ដូចមានឧបសម្ព័ន្ធទី១ ភ្ជាប់មកជាមួយ ។

**មាត្រា ២ .-**

ត្រូវបានលុបឈ្មោះចេញពីក្របខ័ណ្ឌ នូវមន្ត្រី បុគ្គលិក រាជការស៊ីវិល ដែលស្លាប់នៅតាមក្រសួង ស្ថាប័ន និងខេត្ត-ក្រុងនានា ចំនួន ៥៨១ នាក់ ដូចមានឧបសម្ព័ន្ធ ទី២ ភ្ជាប់មកជាមួយ ។

**មាត្រា ៣ .-**

ត្រូវបានដាក់អោយចូលនិវត្តន៍ ចំពោះមន្ត្រី បុគ្គលិក រាជការស៊ីវិល ដែលដល់អាយុចូលនិវត្តន៍ នៅតាមក្រសួង ស្ថាប័ន និងខេត្ត-ក្រុងនានា ចំនួន ៥៦០ នាក់ ដូចមានឧបសម្ព័ន្ធ ទី៣ ភ្ជាប់មកជាមួយ ។

**មាត្រា ៤ .-**

ត្រូវបានលុបឈ្មោះចេញពីតារាងបៀវត្ស ចំពោះមន្ត្រី បុគ្គលិក រាជការស៊ីវិល ដែលបានផ្ទេរចេញទៅបំរើការងារនៅតាមក្រសួង ស្ថាប័ន និងខេត្ត-ក្រុងនានា ចំនួន ១.៨៨៧ នាក់ ដូចមានឧបសម្ព័ន្ធ ទី៤ ភ្ជាប់មកជាមួយ ។

មាត្រា ៥ .-

ការលុបឈ្មោះចេញពីក្របខ័ណ្ឌ ការដាក់អោយចូលនិវត្តន៍ និងការលុបឈ្មោះចេញពីតារាងបៀវត្ស ចំពោះមន្ត្រី បុគ្គលិក រាជការស៊ីវិល ដែលមានចែងក្នុងមាត្រា ១-២-៣ និង ៤ ត្រូវអនុវត្តអោយបាន ត្រឹមត្រូវតាមច្បាប់ និងស្របទៅតាមនីតិវិធី ជាធរមាន រួចហើយត្រូវជំរះចេញអោយអស់ពីតារាងបៀវត្ស ចាប់ពីខែកញ្ញា ឆ្នាំ២០០០ តទៅ ។

មាត្រា ៦ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែល ពាក់ព័ន្ធ អភិបាលគ្រប់ខេត្ត-ក្រុង និងមន្ត្រី បុគ្គលិក រាជការ ស៊ីវិល ដែលមានឈ្មោះចែងក្នុង ឧបសម្ព័ន្ធ ទី១ ទី២ ទី៣ និងទី៤ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

ហត្ថលេខា

សុខ អាន

★★★

## អនុក្រឹត្យ លេខ ៥៤ អនក្រ.បក

## ស្តីពី

## ការកែតម្រូវអនុក្រឹត្យលេខ ២៣ អនក្រ.បក ស្តីពីការអភិវឌ្ឍន៍តំបន់កំពង់ផែស្វយ័ត ក្រុងព្រះសីហនុ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើត កំពង់ផែស្វយ័តក្រុងព្រះសីហនុ